# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

## ផ្នែកទី១៖ វិធីសាស្ត្រអង្កេត



# បុព្វកថា

អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ បានផ្ដល់កាលានុវត្តភាពយ៉ាងសំខាន់ដល់ការវាយតម្លៃអំពីផលិតភាពកសិកម្មនៅកម្ពុជា និងបានបង្ហាញទិន្នន័យស្ថិតិអំពីផ្នែកដំណាំ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម ការនេសាទ និងសកម្មភាពពាក់ព័ន្ធដទៃទៀតដែលមានសារៈប្រយោជន៍បំផុត សម្រាប់ការឆ្លុះបញ្ចាំងអំពីស្ថានភាពផ្នែកបច្ចេកទេសកសិកម្ម បរិស្ថាន សេដ្ឋកិច្ច និងសង្គម គ្រួសារកសិកម្មកម្ពុជា ព័ត៌មាន សន្តិសុខស្បៀងនៃគ្រួសារកសិកម្ម ជាលក្ខណៈនៃរចនាសម្ព័ន្ធកសិកម្ម ដើម្បីធ្វើជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០២៣-២០២៨ ក៏ដូចជាកាត់បន្ថយភាពក្រីក្រ ការគណនាកំណើនសេដ្ឋកិច្ចជាតិ និងកម្មវិធីអភិវឌ្ឍន៍ពាក់ព័ន្ធដទៃទៀត។

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់បំផុត ដើម្បីផ្ដល់ទិន្នន័យប្រកបដោយភាពទុកចិត្ត និងទាន់ពេល សម្រាប់អ្នកតាក់តែងគោលនយោបាយ អ្នកធ្វើសេចក្ដីសម្រេចចិត្តនានារបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់ទូទៅ។ របាយការណ៍អង្កេតកសិកម្មឆ្លុះបញ្ចាំងអំពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ឆ្ពោះទៅសម្រេចឱ្យបានទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ដែលផ្ដោតលើគោលដៅសូចនាករសំខាន់ៗ រួមមាន៖

- គោលដៅទី១៖ ការបញ្ចប់ភាពក្រីក្រ
- គោលដៅទី២៖ ការបញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាព អាហារូបត្ថម្ភ និងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព
- គោលដៅទី៥៖ សម្រេចឱ្យបានសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប។

របាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ នឹងផ្ដល់សារប្រយោជន៍ដល់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍនានា គ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យសាធារណៈ និងឯកជនទូទៅ អាចប្រើប្រាស់របកគំហើញនៅក្នុងរបាយការណ៍អង្កេតខាងលើតាមតម្រូវការ សម្រាប់ធ្វើជាមូលដ្ឋានគ្រឹះក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យរបស់ប្រទេសកម្ពុជានៅឆ្នាំ២០៥០ ដែលត្រូវបានចាត់ទុកការអភិវឌ្ឍវិស័យកសិកម្ម គឺជាយុទ្ធសាស្ត្រស្នូលនៃយុទ្ធសាស្ត្របញ្ចកោណក្នុងដំណាក់កាលទីមួយ។

ក្នុងនាមក្រសួងផែនការ ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែង និងសូមថ្លែងអំណរគុណចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ គម្រោងគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍ស្ថិតិ

កសិកម្ម៥០x២០៣០ គណៈកម្មការបច្ចេកទេសអង្កេតកសិកម្មកម្ពុជា ដៃគូអភិវឌ្ឍនានា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន ក្រុមការងារបច្ចេកទេសអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ ដែលបានចូលរួមអនុវត្តក្នុងដំណើរការ និងការប្រព្រឹត្តទៅនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ឱ្យសម្រេចបានលទ្ធផលជោគជ័យប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងអាណត្តិទី៦ និងជាពិសេស **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានគាំទ្រប្រព័ន្ធការងារស្ថិតិជាតិ និងផ្តល់ថវិកាបដិភាគរាជរដ្ឋាភិបាលសម្រាប់អនុវត្តអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ឱ្យសម្រេចបានជាស្ថាពរ។

**រដ្ឋមន្ត្រី**

**ប៊ិន ត្រាឈៃ**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានក្តីសោមនស្សរីករាយដោយបានបង្ហាញនូវរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ដែលទទួលបានពីការធ្វើសម្ភាសន៍គ្រួសារកសិកម្មសំណាកគំរូប្រមាណ ១៦,០០០គ្រួសារ នៅទូទាំង២៥ រាជធានី ខេត្ត។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ គឺត្រូវបានធ្វើឡើងជាលើកទីបី គិតចាប់តាំងពីឆ្នាំ២០១៩មក។ ការវិភាគរបាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ត្រូវបានដឹកនាំប្រតិបត្តិដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងសហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងដៃគូអភិវឌ្ឍគម្រោងកម្មវិធីគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ស្ថិតិកសិកម្ម៥០x២០៣០។

ការអនុវត្តអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ត្រូវបានអនុវត្តន៍ដោយអនុលោមតាមកិច្ចព្រមព្រៀងរវាងក្រសួងផែនការ ជាមួយនិងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FAO) នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ។ ការងារអង្កេតខាងលើត្រូវបានធ្វើសម្ភាសន៍ផ្ទាល់ដោយប្រើប្រាស់កុំព្យូទ័រជំនួយ (ឬហៅថា CAPI)ដោយប្រើកម្មវិធីសឺវេសូឡូស្សិន (Survey Solution) របស់ធនាគារពិភពលោក សម្រាប់សម្ភាសន៍ ស្រង់ទិន្នន័យ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យអង្កេត។ ទិន្នន័យដែលសម្ភាសន៍បានពីគ្រួសារកសិកម្មសំណាកគំរូ គឺត្រូវបានវិភាគបញ្ចូលនៅក្នុងរបាយការណ៍អង្កេតកសិកម្មកម្ពុជា រួមមានដូចជា៖ ផលិតកម្មដំណាំ បសុសត្វ បសុបក្សី វារីវប្បកម្ម និងនេសាទ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ និងបំពេញតម្រូវការរបស់អ្នកធ្វើគោលនយោបាយ របាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍កសិកម្ម បរិស្ថាន និងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ របស់រាជរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ អ្នកសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀត។

របាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ គឺជាមូលដ្ឋានធាតុចូលដ៏សំខាន់ ក្នុងការរៀបចំកម្មវិធីគោលនយោបាយអភិវឌ្ឍន៍លើវិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផល និងការគាំទ្រសូចនាករគោលដៅឆ្ពោះទៅរក "យុទ្ធសាស្ត្របញ្ចកោណ" ដំណាក់កាលទីមួយ របស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលដៅដែលបានរំពឹងទុកនៅក្នុង "ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០" ។

របាយការណ៍អង្កេតកសិកម្មខាងលើ ក៏ត្រូវបានបើកចំហសម្រាប់កិច្ចពិភាក្សា ព្រមទាំងទទួលនូវរាល់មតិយោបល់ ឬអនុសាសន៍ ដើម្បីកែលម្អរបាយការណ៍វិភាគលទ្ធផលទិន្នន័យអង្កេតកសិកម្មកម្ពុជានាពេលខាងមុខឱ្យកាន់តែប្រសើរថែមទៀត។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន គណៈកម្មការបច្ចេកទេសអង្កេតកសិកម្មកម្ពុជា ក្រុមការងារបច្ចេកទេសអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ អ្នកជំនាញការអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និង ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានចូលរួមអនុវត្តន៍ការងារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ឱ្យសម្រេចបាន ជោគជ័យ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ទ្រី ឫទ្ធា**

# អក្សរកាត់

| | | |
|---|---|---|
| CAS | អង្កេតកសិកម្មកម្ពុជា | Cambodia Agriculture Survey |
| CIAS | អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា | Cambodia Inter-Censal Agriculture Survey |
| CSES | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | Cambodia Socio-Economic Survey |
| FAO | អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ | Food and Agriculture Organization |
| GDP | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product |
| Ha | ហិកតា | Hectare |
| Kg | គីឡូក្រាម | Kilograms |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Ministry of Agriculture Forestry and Fisheries |
| MOP | ក្រសួងផែនការ | Ministry of Planning |
| NIS | វិទ្យាស្ថានជាតិស្ថិតិ | National Institute of Statistics |
| PPS | ទំហំសមាមាត្រចៃដន្យ | Probability Proportional to Size |
| RGC | រាជរដ្ឋាភិបាលកម្ពុជា | Royal Government of Cambodia |
| TC | គណៈកម្មាធិការបច្ចេកទេស | Technical Committee |
| USD | ដុល្លារអាមេរិក | United States Dollar |

# របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

របាយការណ៍នេះ ចែកជាប្រាំផ្នែកដែលគ្របដណ្តប់នូវទិដ្ឋភាពសំខាន់ៗ ផ្សេងគ្នាដូចខាងក្រោម៖

**ផ្នែកទី១៖ ឯកសារយោងនៃវិធីសាស្ត្រប្រមូលទិន្នន័យ**

ផ្នែកនេះគ្របដណ្តប់នូវព័ត៌មាន នៃការអង្កេតទាំងមូលរួមមាន៖ បុព្វកថា អារម្ភកថា អក្សរកាត់ សូចនាករ សង្ខេបនៃវិធីសាស្ត្រអង្កេត វិសាលភាពនៃការអង្កេត ទីតាំងភូមិសាស្ត្រ រយៈពេលនៃការអង្កេត កាលបរិច្ឆេទយោង និងតារាងបញ្ជីសំណាកគំរូ ។

**ផ្នែកទី២៖ ផលិតកម្មដំណាំ**

ផ្នែកនេះគ្របដណ្តប់លើផលិតកម្មដំណាំក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងព័ត៌មានទាក់ទងនឹងចំនួនគ្រួសារកាន់កាប់កសិកម្ម ផលិតកម្មដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែង។ ការប្រើប្រាស់ផ្ទៃដីកសិកម្ម ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ទិន្នផលដំណាំ ការប្រើប្រាស់ជី ប្រព័ន្ធធារាសាស្ត្រ ប្រភេទគ្រាប់ពូជ/ពូជរុក្ខជាតិដាំដុះ ប្រភេទដីដែលប្រើប្រាស់ ផលប៉ះពាល់នៃសំណឹកដី និងតម្លៃនៃការលក់ផលិតផលដំណាំ។

**ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ បសុបក្សី**

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់គ្រួសារកសិកម្ម រួមបញ្ចូលទាំងចំនួនគ្រួសារចិញ្ចឹមបសុសត្វ និងបសុបក្សី ចំនួនសត្វសរុបនៅក្នុងប្រទេសកម្ពុជា ចំនួនសត្វជាមធ្យមក្នុងមួយគ្រួសារ គោលបំណងនៃការចិញ្ចឹមសត្វ តម្លៃនៃការលក់សត្វ និងថ្លៃដើមផលិត។

**ផ្នែកទី៤៖ វារីវប្បកម្ម និងនេសាទ**

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់គ្រួសារកសិកម្ម ដែលពាក់ព័ន្ធនឹងវារីវប្បកម្ម និងនេសាទ រួមបញ្ចូលទាំងចំនួនគ្រួសារធ្វើវារីវប្បកម្មតាមប្រភេទផ្សេងៗគ្នា ចំនួនផ្ទៃដីសរុបសម្រាប់វារីវប្បកម្ម ប្រភេទវារីសត្វចិញ្ចឹម និងបរិមាណផលិត គ្រួសារចូលរួមក្នុងសកម្មភាពនេសាទតាម ប្រភេទទឹក ប្រភេទវារីសត្វ និងបរិមាណសរុបនេសាទបាន។

**ផ្នែកទី៥៖ កម្លាំងពលកម្ម និងសកម្មភាពសេដ្ឋកិច្ច**

របាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ សម្រាប់ផ្នែកនេះ បញ្ចូលនូវព័ត៌មានអំពីកម្លាំងពលកម្មជាសមាជិកគ្រួសារ និងការជួលមិនមែនជាសមាជិកគ្រួសារធ្វើការក្នុងកសិដ្ឋាន។ តម្លៃជួល និងការចំណាយលើការងារធ្វើកសិកម្ម ទិន្នផលទទួលបានពីកសិកម្ម គោលបំណងចម្បងផលិតកម្មកសិកម្ម ប្រាក់ឈ្នួលនិយោជិតពីខាងក្រៅ ផលចំណេញ ការចូលរួមនៅក្នុងសមាគមកសិករ គ្រោះធម្មជាតិ/គ្រោះមហន្តរាយ ដែលគ្រួសារជួបប្រទះ និងការឆ្លើយតបចំពោះគ្រោះហានិភ័យធម្មជាតិ/ជំងឺរាតត្បាតផ្សេងៗ ការធានារ៉ាប់រង ឥណទាន ប្រាក់កម្ចី និងប្រាក់សន្សំ ។

ផ្នែកទាំងប្រាំខាងលើអាចទាញយកពីគេហទំព័រ https://www.nis.gov.kh របស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅ នៃទិន្នន័យដែលមាននៅក្នុងការអង្កេតកសិកម្មឆ្នាំ២០២១។ ការសរសេររបាយការណ៍វិភាគនេះ បានដកស្រង់យកចំណុចសំខាន់ៗ ហើយទិន្នន័យបង្ហាញតែនៅកម្រិតថ្នាក់ជាតិ និង តំបន់។ អ្នកប្រើប្រាស់ទិន្នន័យត្រូវបានលើកទឹកចិត្តអាចស្វែងរកដោយខ្លួនឯង ដោយប្រើតារាងទិន្នន័យលម្អិត ដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រទិន្នន័យ CAMSAT https://camstat.nis.gov.kh និង Microdata https://microdata.nis.gov.kh ។

# សេចក្តីសង្ខេប

## ទិដ្ឋភាពទូទៅ នៃវិធីសាស្ត្រអង្កេត

អង្កេតកសិកម្មកម្ពុជាត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០២១ ក្នុងគោលបំណងដើម្បីប្រមូល ចងក្រង ព័ត៌មាន វិភាគទិន្នន័យស្ថិតិកសិកម្មស៊ីជម្រៅក្នុងផ្នែកការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងការនេសាទ។ ទិន្នន័យស្ថិតិដែលប្រមូលបានពីការអង្កេតនេះផ្តល់សារៈប្រយោជន៍ដល់អ្នករៀបចំធ្វើផែនការគោលនយោបាយ និងកម្មវិធីអភិវឌ្ឍនានាសម្រាប់ការលើកកម្ពស់គុណភាពវិស័យកសិកម្មនៅប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នរបស់រដ្ឋាភិបាលដែលមានតួនាទីទទួលខុសត្រូវ និងបានទទួលការអនុញ្ញាតឱ្យធ្វើការអង្កេតនេះ។ វិទ្យាស្ថានជាតិស្ថិតិ មានតួនាទី និងភារកិច្ចក្នុងការប្រមូល ចងក្រង វិភាគទិន្នន័យស្ថិតិតាមរយៈការធ្វើជំរឿន និងអង្កេតនានា ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ជាចម្បងនូវទិន្នន័យអង្កេតនេះ។

គោលបំណងចម្បង នៃការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ដើម្បីផ្តល់ទិន្នន័យស្តីពីស្ថានភាពវិស័យកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ដល់អ្នករៀបចំផែនការ កសាងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍ ផ្សេងៗរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ ការជ្រើសរើសសំណាកគំរូអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ បានធ្វើឡើងផ្អែកលើការចុះបញ្ជីគ្រួសារកសិកម្មថ្មី បន្ទាប់ពីបានប្រើប្រាស់សំណាកគំរូដដែលសម្រាប់ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ បានប្រើប្រាស់តាមវិធីសាស្ត្រស្ថិតិ ដោយការជ្រើសរើសសំណាកគំរូចេញពីបញ្ជីមណ្ឌលជំរឿននៅទូទាំងប្រទេស ដែលបានមកពីការធ្វើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ជាបញ្ជីសំណាកគំរូ (Sampling Frame) គ្រួសារទាំងអស់ដែលនៅក្នុងមណ្ឌលជំរឿន ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីគ្រួសារដើម្បីស្វែងរកគ្រួសារធ្វើសកម្មភាពកសិកម្ម។ ការប្រើប្រាស់ព័ត៌មានសំណាកគំរូនេះ សម្រាប់ជាមូលដ្ឋានក្នុងការបែងចែកគ្រួសារកាន់កាប់កសិកម្មទៅជាក្រុមៗ ដើម្បីកំណត់យកគ្រួសារសំណាកគំរូ សម្រាប់សម្ភាសន៍ប្រមូលទិន្នន័យអង្កេតកសិកម្ម ដោយផ្តោតសំខាន់លើការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ និងសហគ្រាសកសិកម្មខ្នាតធំចំនួន ៤៧០ ត្រូវបានធ្វើសម្ភាសន៍ផងដែរ ប៉ុន្តែការវិភាគទិន្នន័យសហគ្រាសកសិកម្មខ្នាតធំនេះ ពុំត្រូវបានបញ្ចូលក្នុងរបាយការណ៍នេះទេ។ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ សំដៅទៅលើសហគ្រាសដែលដំណើរការជាលក្ខណៈក្រុមហ៊ុន សាជីវកម្ម សហគមន៍ គ្រឹះស្ថានរដ្ឋ និងឯកជន។ កិច្ចខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ត្រូវបានធ្វើឡើងបន្ទាប់ពីបានស្វែងរកឃើញបញ្ជីឈ្មោះសហគ្រាសកសិកម្មខ្នាតធំដែលបានចុះបញ្ជីប្រតិបត្តិការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នផ្សេងទៀតនៃរដ្ឋាភិបាល ដែលមានព័ត៌មានអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ។

ការប្រមូលទិន្នន័យអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍អ្នកផ្តល់ចម្លើយដោយផ្ទាល់ និងប្រើប្រាស់ម៉ាស៊ីនថេប្លេត។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអង្កេត (Survey Solutions) របស់ធនាគារពិភពលោក។ ការប្រើប្រាស់កម្មវិធីកាពី (CAPI) សម្រាប់សម្ភាសន៍ គឺចំណេញពេលវេលា មិនចំណាយលើការវាយបញ្ចូលទិន្នន័យ បង្កើនសមត្ថភាពចំណេះដឹងជំនាញលើបច្ចេកវិទ្យាកុំព្យូទ័រ និងការត្រួតពិនិត្យគុណភាព និងមានលទ្ធភាពទាញតារាងស្ថិតិធ្វើការវិភាគទិន្នន័យបានឆាប់រហ័សជាងមុន។

សំណាកគំរូគ្រួសារកសិកម្ម ដែលរស់នៅទូទាំងប្រទេសត្រូវបានជ្រើសរើសយកមកធ្វើការសម្ភាស លើកលែងខណ្ឌចំនួន ៦ នៅរាជធានីភ្នំពេញ ក្រុងចំនួន១ នៅខេត្តព្រះសីហនុ និងក្រុងចំនួន១ នៅខេត្តសៀមរាប ត្រូវបានចាត់ជាទីប្រជុំជន និងមិនបានរាប់បញ្ចូលក្នុងការអង្កេតនះទេ។ សម្រាប់ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ គ្រួសារសំណាកគំរូសរុបចំនួន ១៦.៥៧២ គ្រួសារកសិកម្ម និងការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំចំនួន ៤៧០ ត្រូវបានសម្ភាសន៍។

ព័ត៌មានលម្អិតអំពីនីតិវិធីនៃការជ្រើសរើស សំណាកគំរូ វិធីសាស្ត្រអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យសម្រាប់អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ មានការអធិប្បាយពន្យល់លម្អិតនៅក្នុងជំពូកទី១ – វិសាលភាពការគ្របដណ្តប់ និងការជ្រើសរើសសំណាកគំរូ។ ការសម្ភាសផ្នែកគ្រួសារកាន់កាប់កសិកម្មបានធ្វើឡើងពីថ្ងៃទី១៣ ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ចំណែកការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ។ កាលបរិច្ឆេទយោងសម្រាប់ការអង្កេតនេះ គឺក្នុងរយៈពេល១២ខែកន្លងមក ដោយគិតចាប់ពី ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ មានមន្ត្រីសម្ភាសន៍សរុបចំនួន ៣៣៧ នាក់ ចូលរួមក្នុងការចុះសម្ភាសប្រមូលទិន្នន័យនេះ មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យចំនួន ៤៦ នាក់ ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ និងមន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ចំនួន ៤៦ នាក់ ទទួលខុសត្រូវជួយសម្របសម្រួលមន្ត្រីសម្ភាសន៍ ក្នុងការដោះស្រាយបញ្ហានៅតាមមូលដ្ឋាន ជួយទំនាក់ទំនងជាមួយមេភូមិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយគ្រួសារកាន់កាប់កសិកម្មឲ្យបានដំណើរការរលូននៅក្នុងប្រតិបត្តិការអង្កេតនេះ។ មន្ត្រីទាំងនេះជ្រើសរើសចេញពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីនៅតាមមន្ទីរផែនការខេត្ត មន្ទីរកសិកម្មរុក្ខា ប្រមាញ់ និងនេសាទខេត្ត ។

ការអង្កេតកសិកម្មកម្ពុជាបានប្រើប្រាស់និយមន័យ "គ្រួសារកាន់កាប់កសិកម្ម" ដែលកំណត់ក្នុងឯកសារណែនាំស្តីអំពីជំរឿនកសិកម្មពិភពលោកដែលបានបោះផ្សាយឆ្នាំ២០២០ និងយុទ្ធសាស្ត្រសកលដើម្បីលើកកម្ពស់ស្ថិតិកសិកម្ម និងជនបទ។ ការកាន់កាប់កសិកម្មត្រូវបានកំណត់ថា៖ ជាអង្គភាពសេដ្ឋកិច្ច នៃផលិតកម្មកសិកម្មស្ថិតក្រោមការគ្រប់គ្រងតែមួយ ដែលរួមមាន បសុសត្វ បសុបក្សី ដែលបានរក្សាទុក និងផ្ទៃដី ដែលបានប្រើប្រាស់ទាំងស្រុង ឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្ម ដោយមិនគិតពី

ស្ថានភាព កម្មសិទ្ធិ ទម្រង់នៃការកាន់កាប់ ឬទំហំឡើយ។ ការគ្រប់គ្រងណាមួយ អាចត្រូវបានអនុវត្តន៍ដោយបុគ្គល

ឬគ្រួសារដោយបុគ្គលពីរនាក់ ច្រើននាក់ ឬច្រើនគ្រួសាររួមគ្នា ជាក្រុម ឬកុលសម្ព័ន្ធ ឬដោយនីតិបុគ្គលដូចជា សាជីវកម្ម សហគមន៍ ឬស្ថាប័នរដ្ឋាភិបាល។ ដីនៅដែលស្ថិតក្រោមការកាន់កាប់កសិកម្ម អាចមានក្បាលដីមួយ ឬច្រើន ដែលមានទីតាំងនៅតំបន់ដាច់ដោយឡែកមួយឬច្រើន ឬនៅក្នុងភូមិសាស្ត្រ ឬរដ្ឋបាលដែនដីមួយឬច្រើន ដោយផ្តល់ក្បាលដី ដែលមានមធ្យោបាយផលិតកម្មដូចគ្នា ដូចជា ពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬកម្លាំងអូសទាញ។ វិសាលភាពនៃសកម្មភាពកសិកម្មមានដូចជាការដាំដំណាំរយៈពេលវែង ឬដំណាំរយៈពេលខ្លី ការបង្កាត់ពូជរុក្ខជាតិ ផលិតកម្មសត្វ ឬការធ្វើកសិកម្មចម្រុះ។ សកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មផ្សេងទៀត ដូចជា ការនេសាទ ព្រៃឈើ និងវារីវប្បកម្ម ត្រូវបានចាត់ទុកថាជាពិពិធកម្មនៃការកាន់កាប់កសិកម្ម។

នៅក្នុងការអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ គឺជាការជ្រើសរើសសំណាកគំរូមានកម្រិតកំណត់ ដូច្នេះ ទិន្នន័យដែលផលិត វិភាគបកស្រាយ ឬប្រៀបធៀប ត្រូវពឹងផ្អែកលើប្រភពទិន្នន័យផ្សេងទៀតផងដែរ។ អ្នកប្រើប្រាស់ទិន្នន័យ ឬអ្នកអាន អាចយោងទៅលើរបាយការណ៍អង្កេតកសិកម្មកម្ពុជាពេញលេញ នៅក្នុងផ្នែកដែនកំណត់ នៃជំពូកទី១។ ជាទូទៅអ្នកប្រើប្រាស់ទិន្នន័យ ឬអ្នកអានគួរស្វែងយល់ដោយខ្លួនឯង ពីដែនកំណត់នៃទិន្នន័យអង្កេត វិសាលភាពនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំនៅកម្ពុជាមានកម្រិតកំណត់ និងកម្រងសំណួរអង្កេតដែលបានសម្ភាសន៍ចប់មិនពេញលេញ ។

## សូចនាករសង្ខេប

ការអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ប្រើប្រាស់កម្រងសំណួរជាចម្បងមួយសម្រាប់ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារហើយកម្រងសំណួរដូចគ្នានេះ ក៏ត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំផងដែរ។

ទម្រង់កម្រងសំណួរនេះរួមមាន១១ ជំពូកសំខាន់ៗគឺ៖

១. ការកំណត់អត្តសញ្ញាណរបស់អ្នកឆ្លើយ និងការយល់ព្រមជាមុន

២. ចរិតលក្ខណៈនៃកសិដ្ឋាន

៣. ម្ចាស់កម្មសិទ្ធិដីធ្លី

៤. ផលិតកម្មដំណាំ

៥. ការប្រើប្រាស់គ្រាប់ពូជ និងជី

៦. ផលិតកម្មបសុសត្វ បសុបក្សី

៧. សកម្មភាពវារីវប្បកម្ម និងការនេសាទ

៨. សេដ្ឋកិច្ច

៩. សមាជិកគ្រួសារ
១០. កម្លាំងពលកម្មដែលបានប្រើប្រាស់នៅក្នុងការកាន់កាប់កសិកម្ម
១១. បញ្ចប់ការសម្ភាស

ទិន្នន័យសំខាន់ៗកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ ទាញចេញពីការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ បែងចែកតាមតំបន់ វាលទំនាប បឹងទន្លេសាប ឆ្នេរសមុទ្រ និង ភ្នំនិងខ្ពង់រាប ត្រូវបានបង្ហាញក្នុងតារាងដូចខាងក្រោម៖

**តារាងទី១.១៖ សូចនាករសង្ខេប គ្រួសារកាន់កាប់កសិកម្ម**

| **គ្រួសារកាន់កាប់កសិកម្ម** | | | | | |
|---|---|---|---|---|---|
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារកសិកម្ម (គិតជាពាន់) | 2,226 | 950 | 792 | 156 | 328 |
| **គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារកសិកម្ម៖** | | | | | |
| ចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ | 58% | 58% | 52% | 84% | 59% |
| ចម្បងសម្រាប់លក់ | 42% | 42% | 48% | 16% | 41% |
| ភាគរយនៃគ្រួសារកសិកម្មមានតែដីជុំវិញលំនៅដ្ឋានប៉ុណ្ណោះ | 12% | 11% | 13% | 16% | 9% |

ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១

**តារាងទី១.២ សូចនាករសង្ខេបនៃផលិតកម្មដំណាំ**

| **ផលិតកម្មដំណាំ** | | | | | |
|---|---|---|---|---|---|
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារបានដាំដុះដំណាំ (គិតជាពាន់) | 2,048 | 871 | 732 | 139 | 307 |
| ភាគរយនៃគ្រួសារបានដាំដុះដំណាំ | 92% | 92% | 92% | 89% | 94% |

| | | | | | |
|---|---|---|---|---|---|
| ដំណាំដែលពេញនិយម ចំនួនបួនដែលបានដាំដុះ ដោយគ្រួសារកសិកម្ម | ១.ស្រូវធម្មតា<br>២. ស្វាយ<br>៣. ចេក<br>៤. ដូង | ១.ស្រូវធម្មតា<br>២. ចេក<br>៣. ស្វាយ<br>៤. ដូង | ១.ស្រូវធម្មតា<br>២. ស្វាយ<br>៣. ចេក<br>៤. ដូង | ១.ស្រូវធម្មតា<br>២. ដូង<br>៣. ចេក<br>៤. ស្វាយ | ១.ស្រូវធម្មតា<br>២. ស្វាយ<br>៣. ស្វាយចន្ទី<br>៤. ចេក |

ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១

**តារាងទី១.៣ សូចនាករសង្ខេបនៃផលិតកម្មបសុសត្វ បសុបក្សី**

| សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី | | | | | |
|---|---|---|---|---|---|
| | **ប្រទេសកម្ពុជា** | **តំបន់វាល ទំនាប** | **តំបន់បឹង ទន្លេសាប** | **តំបន់ឆ្នេរ សមុទ្រ** | **តំបន់ភ្នំ និង ខ្ពង់រាប** |
| ចំនួនគ្រួសារកសិកម្មដែលបាន ចិញ្ចឹមបសុសត្វ បសុបក្សី ក្នុង អំឡុងពេលឆ្នាំយោង (គិតជាពាន់) | 1,610 | 651 | 577 | 132 | 250 |
| ភាគរយនៃគ្រួសារកសិកម្ម ដែលបានចិញ្ចឹមបសុសត្វ/បសុ បក្សី ក្នុងអំឡុងពេលឆ្នាំយោង | 72% | 69% | 73% | 85% | 76% |
| ចំនួនគ្រួសារកសិកម្មដែលបាន ចិញ្ចឹមសត្វគោក្នុងអំឡុងពេល ឆ្នាំយោង (គិតជាពាន់) | 780 | 357 | 254 | 60 | 107 |
| ចំនួនសត្វគោជាមធ្យមក្នុងមួយ គ្រួសារ | 4.4 | 4.1 | 4.7 | 2.8 | 5.4 |
| ចំនួនគ្រួសារកសិកម្មដែលបាន ចិញ្ចឹមសត្វមាន់ក្នុងអំឡុងពេល ឆ្នាំយោង (គិតជាពាន់) | 1,232 | 468 | 441 | 122 | 201 |
| ចំនួនសត្វមាន់ជាមធ្យមក្នុង មួយគ្រួសារ | 37.7 | 36.5 | 35.1 | 38.2 | 37.5 |

ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១

**តារាងទី១.៤៖ សូចនាករសង្ខេបនៃសកម្មភាពវារីវប្បកម្ម និងនេសាទ**

| **សកម្មភាពវារីវប្បកម្ម និងនេសាទ** | | | | | |
|---|---|---|---|---|---|
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារកសិកម្មដែលបានចូលរួមធ្វើវារីវប្បកម្ម (គិតជាពាន់) | 89 | 60 | 21 | 5 | 3 |
| ភាគរយគ្រួសារកសិកម្មដែលបានចូលរួមធ្វើវារីវប្បកម្ម | 4% | 6% | 3% | 3% | 1% |
| ចំនួនគ្រួសារកសិកម្មដែលបានចូលរួមសកម្មភាពនេសាទ (គិតជាពាន់) | 477 | 132 | 223 | 37 | 85 |
| ភាគរយគ្រួសារកសិកម្មដែលបានចូលរួមសកម្មភាពនេសាទ | 21% | 14% | 28% | 24% | 26% |

ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១

**តារាងទី១.៥៖ សូចនាករសង្ខេបនៃសកម្មភាពសេដ្ឋកិច្ច**

| **សកម្មភាពសេដ្ឋកិច្ច** | | | | | |
|---|---|---|---|---|---|
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ភាគរយនៃគ្រួសារកសិកម្មដែលមានចំណូលបានមកពីសកម្មភាពកសិកម្មទាំងស្រុង | 4.10% | 2.60% | 5.40% | 4.40% | 5.20% |
| ការចូលរួមចំណែកចំណូលបានពីកសិកម្មជាមួយនឹងចំណូលសរុបគ្រួសារដោយប្រៀបធៀបទៅឆ្នាំមុន៖ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មទាបជាងឆ្នាំមុន | 27% | 24% | 31% | 31% | 23% |

| | | | | | |
|---|---|---|---|---|---|
| ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មប្រហែលគ្នាឆ្នាំមុន | 67% | 69% | 64% | 65% | 71% |
| ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មច្រើនជាងឆ្នាំមុន | 6% | 7% | 5% | 5% | 6% |

ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១

ផ្អែកតាមជំរឿនទូទៅ ប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានខ្នងផ្ទះចំនួន ៣.៥៥៣.០២១ ខ្នង។ ការអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ បានបង្ហាញអំពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារមានប្រមាណ ២.២២៦.000 គ្រួសារ ប្រមាណជា ៦៣% នៃគ្រួសារទាំងអស់នៅកម្ពុជាបានចូលរួមក្នុងផលិតកម្មកសិកម្ម ហើយមានភាគរយប្រមាណជា ១២% នៃគ្រួសារកសិកម្មទាំងអស់បានរាយការណ៍ថា មានសកម្មភាពកសិកម្មតែលើដីបរិវេណជុំវិញលំនៅដ្ឋានរបស់ខ្លួនប៉ុណ្ណោះ ពោលគឺមានចំនួនភាគរយរក្សានៅដដែលបើពិនិត្យមើលកាលពីជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ ។ យោងតាមអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ គ្រួសារកសិកម្មនីមួយៗមានការកាន់កាប់ក្បាលដីជាមធ្យមប្រមាណ ១,៥ក្បាលដី ប៉ុណ្ណោះចំណែកឯជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៣ បានប៉ាន់ប្រមាណថា គ្រួសារកសិកម្មកាន់កាប់ក្បាលដីជាមធ្យមដល់ទៅ ២,៥ ក្បាលដី។

គ្រួសារកសិកម្មចំនួន ៩២% នៃគ្រួសារកសិកម្មទាំងអស់នៅកម្ពុជាបានរាយការណ៍អំពីសកម្មភាពដាំដំណាំ។ ដំណាំចម្បងរួមមាន៖ ១)ដំណាំស្រូវធម្មតា ២)ដំណាំស្វាយ ៣)ដំណាំចេក និង ៤)ដំណាំដូង។ ចំនួន ៧២% នៃគ្រួសារកសិកម្មទាំងអស់ រាយការណ៍ពីការចិញ្ចឹមបសុសត្វ បសុបក្សី ឬសត្វល្អិត។ គ្រួសារដែលបានរាយការណ៍ថាបានចិញ្ចឹមគោ មានចំនួន ៧៨០.000 គ្រួសារ ចិញ្ចឹមមាន់មានចំនួន ១,២ លានគ្រួសារ នៅក្នុងឆ្នាំយោង១២ ខែកន្លងមក។ ចំណែកឯការធ្វើវារីវប្បកម្មវិញមានចំនួនប្រមាណ ៤ % និងគ្រួសារធ្វើសកម្មភាពនេសាទមានចំនួនប្រមាណ ២១% នៃគ្រួសារកសិកម្មសរុប។

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ក៏បានសួរសំណួរផ្នែកសេដ្ឋកិច្ចជាច្រើនផងដែរ គ្រួសារកសិកម្មត្រូវបានស្នើឱ្យប៉ាន់ស្មានចំណែក នៃប្រាក់ចំណូលសរុបប្រចាំគ្រួសារ ដែលត្រូវបានគណនាជាប្រាក់ចំណូលពីកសិកម្មរបស់ខ្លួន។ មានចំនួន ៤.១% បានរាយការណ៍ថា ប្រាក់ចំណូលសរុបទាំងអស់ប្រចាំគ្រួសាររបស់ខ្លួនបានមកពីកសិកម្ម។

លើសពីនេះ គ្រួសារទាំងនោះត្រូវបានស្នើឱ្យបង្ហាញប្រាក់ចំណូលពីកសិកម្មរបស់ខ្លួនក្នុងអំឡុងពេលយោង ធៀបនឹងប្រាក់ចំណូលពីកសិកម្មក្នុងអំឡុងឆ្នាំមុន។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ប៉ាន់ប្រមាណថា ២៧% នៃគ្រួសារកសិកម្មបានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មរបស់ខ្លួនមានទាបជាងឆ្នាំមុន ៦៧% បានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មប្រហែលនឹងឆ្នាំមុន ហើយ ៦% បានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មមានច្រើនជាងឆ្នាំមុន។

## ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ នៅព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឡើងក្នុងឆ្នាំ២០២០-២០២១ គឺជាកិច្ចការ ប្រមូល និងចងក្រងព័ត៌មានស្ថិតិមានលក្ខណៈស៊ីជម្រៅ ផ្តោតលើការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងនេសាទ។ ទិន្នន័យដែលប្រមូលបានពីការអង្កេតនេះមានសារៈសំខាន់បំផុតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំផែនការ គោលនយោបាយ កម្មវិធីអភិវឌ្ឍនានា ដើម្បីលើកកម្ពស់ វិស័យកសិកម្ម និងជលផលនៅកម្ពុជា ។ អង្កេតកសិកម្មប្រចាំឆ្នាំ២០២០ គឺជាអង្កេតលើកដំបូង បន្ទាប់ពីធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៩ នៅព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នរបស់ រដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល និងមានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ នេះ។ វិទ្យាស្ថានជាតិស្ថិតិ មានតួនាទី និងភារកិច្ចធ្វើជំរឿន និងអង្កេត ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ចម្បងនៃទិន្នន័យដែលផលិតចេញពីការអង្កេតនេះ។

### គោលបំណង

ការអង្កេតកសិកម្មកម្ពុជា នេះមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ដីពីសកម្មភាពកសិកម្មនៅ ព្រះរាជាណាចក្រកម្ពុជា ដែលប្រើប្រាស់ដោយអ្នករៀបចំផែនការ និងអ្នកកសាងគោលនយោបាយ។ ជាពិសេសទិន្នន័យអង្កេតនេះផ្តល់សារៈប្រយោជន៍ ៖

១. ការផ្តល់បញ្ជីឈ្មោះមណ្ឌលជំរឿនដែលបានធ្វើបច្ចុប្បន្នភាពនៅក្នុងការអង្កេតកសិកម្មកម្ពុជា

២. ការផ្តល់ទិន្នន័យនៅថ្នាក់ជាតិ និងតំបន់ ក្នុងនោះធាតុមួយចំនួនក៏មាននៅថ្នាក់ខេត្តផងដែរ

៣. ការផ្តល់ទិន្នន័យអំពីរចនាសម្ព័ន្ធបច្ចុប្បន្ននៃការកាន់កាប់កសិកម្មនៅកម្ពុជា ដូចជា ការដាំដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ព្រមទាំងការធ្វើវារីវប្បកម្ម និងនេសាទ។

វិសាលភាពគ្របដណ្តប់ទាំងមូលនៃការអង្កេតនេះ មាននៅក្នុងកម្រងសំណួរលម្អិតដែលមាននៅក្នុងឧបសម្ព័ន្ធទី២នៃរបាយការណ៍នេះ។ ទិន្នន័យទាំងនេះបង្កើតសក្តានុពលសម្រាប់ការវិភាគទូលំទូលាយដែលអាចធំជាងវិសាលភាពនៃរបាយការណ៍នេះ។ គួរកត់សំគាល់ថា របាយការណ៍នេះរួមបញ្ចូលទិន្នន័យ

នៅថ្នាក់ជាតិ និងថ្នាក់តំបន់ជាមួយទិន្នន័យនៅថ្នាក់ខេត្ត ដែលមានជាតារាងនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (https://www.nis.gov.kh) ឬតារាងលម្អិតតាមរយៈ(https://microdata.nis.gov.kh/index.php) ។

## វិធីសាស្ត្រ

ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ប្រើប្រាស់សំណាកគំរូដូចគ្នា ចំពោះការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ប្រើប្រាស់សំណាកគំរូថ្មី។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ប្រើប្រាស់មណ្ឌលជំរឿនជាគោលជ្រើសរើសចេញពីជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩។ គ្រួសារដែលរស់នៅក្នុងមណ្ឌលជំរឿនទាំងនោះត្រូវបានចុះបញ្ជីគ្រួសារដើម្បីស្វែងរកសកម្មភាពកសិកម្មទាំងឡាយដែលមាន ដោយប្រើព័ត៌មាននេះជាមូលដ្ឋានគ្រួសារកសិកម្មត្រូវបានចាត់ថ្នាក់ និងជ្រើសរើសយកជាសំណាកគំរូ សម្រាប់ការប្រមូលទិន្នន័យបន្ថែម។ កិច្ចខិតខំប្រឹងប្រែងប្រមូលទិន្នន័យក្នុងពេលដំណាលគ្នាដោយផ្តោតលើការកាន់កាប់កសិកម្មមិនមែនគ្រួសារ ឬសហគ្រាសកសិកម្មខ្នាតធំ ដែលទទួលបាន បញ្ជីឈ្មោះពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានជាតិស្ថិតិ ការិយាល័យខេត្ត និងភាគីពាក់ព័ន្ធផ្សេងទៀត។

មន្ត្រីសម្ភាសន៍ត្រូវបានជ្រើសរើសមកពីមន្ទីរផែនការ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។ មន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ ( FS ) និងមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ ( DS ) ត្រូវបានជ្រើសរើសពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យទាំងអស់ត្រូវបានធ្វើការបណ្តុះបណ្តាលមុននឹងចុះប្រតិបត្តិការអង្កេតនេះ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងទាំងពីរ បានធ្វើឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីការប្រមូលទិន្នន័យ រហូតដល់ការវិភាគ និងចងក្រងទិន្នន័យ។

ការប្រមូលទិន្នន័យអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍អ្នកផ្តល់ចម្លើយដោយផ្ទាល់ និងប្រើប្រាស់ម៉ាស៊ីនថេប្លេត។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអង្កេត (Survey Solutions) របស់ធនាគារពិភពលោក។ ការប្រើប្រាស់កម្មវិធីកាពី (CAPI) សម្រាប់សម្ភាសន៍ គឺចំណេញពេលវេលា មិនចំណាយលើការវាយបញ្ចូលទិន្នន័យ បង្កើនសមត្ថភាពចំណេះដឹងជំនាញលើបច្ចេកវិទ្យាកុំព្យូទ័រ និងការត្រួតពិនិត្យគុណភាព និងមានលទ្ធភាពទាញតារាងស្ថិតិធ្វើការវិភាគទិន្នន័យបានឆាប់រហ័សជាងមុន។

## ទំហំគំរូ នៃការអង្កេត

កម្រងសំណួរបានប្រមូលទិន្នន័យផ្តោតលើទិដ្ឋភាពមួយចំនួននៃការកាន់កាប់កសិកម្ម រួមទាំងព័ត៌មានប្រជាសាស្ត្រ សហកម្មសិទ្ធិករ សមាជិកគ្រួសារ សកម្មភាពផលិតកម្មដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី សកម្មភាពវារីវប្បកម្ម និងនេសាទ ស្ថានភាពសេដ្ឋកិច្ចក្នុងអំឡុងពេល១២ខែកន្លងមក កម្លាំងពលកម្មដែលប្រើប្រាស់នៅក្នុងកសិដ្ឋាន ព័ត៌មានអំពីលំនៅដ្ឋាន និងទ្រព្យសម្បត្តិគ្រួសារ។ សំណួរបន្ថែមថ្មីសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ គឺផ្តោតលើវិស័យសេដ្ឋកិច្ច និងសូចនាករសេដ្ឋកិច្ចសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ( SDG ២.៤.១) ។

## ទីតាំងភូមិសាស្ត្រគ្របដណ្តប់

សំណាកគំរូគ្រួសារកសិកម្ម ដែលរស់នៅទូទាំងប្រទេសត្រូវបានជ្រើសរើសយកមកធ្វើការសម្ភាស លើកលែងខណ្ឌចំនួន ៦ នៅរាជធានីភ្នំពេញ ក្រុងចំនួន១ នៅខេត្តព្រះសីហនុ និងក្រុងចំនួន១ នៅខេត្តសៀមរាប ត្រូវបានចាត់ជាទីប្រជុំជន និងមិនបានរាប់បញ្ចូលក្នុងការអង្កេតនេះទេ។ គ្រួសារកសិកម្ម គឺមាន សក្តានុពលក្នុងការជ្រើសរើសជាសំណាកគំរូ នៃអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ និងបន្ទាប់មកក្លាយជាសំណាកគំរូសម្រាប់ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ត្រូវបានជ្រើសរើសគ្រួសារកសិកម្មសំណាកគំរូសរុបចំនួន ១៦.៥៧២ និងការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំចំនួន ៤៧០ កសិដ្ឋានត្រូវបានសម្ភាសន៍ផងដែរ។

បន្ថែមពីលើការងារប្រមូលទិន្នន័យតាមគ្រួសារកសិកម្ម ក៏មានការប្រមូលទិន្នន័យដាច់ដោយឡែកផ្តោតលើការកាន់កាប់កសិកម្មមិនមែនគ្រួសារផងដែរ (សហគ្រាសកសិកម្មខ្នាតធំ) ដែលដំណើរការជាក្រុមហ៊ុន សាជីវកម្ម សហគមន៍ ស្ថាប័នរដ្ឋាភិបាល និងឯកជន។ ដោយហេតុថា ការកាន់កាប់មួយចំនួនពុំមានដំណើរការអាជីវកម្មក្នុងកាលបរិច្ឆេទយោង ដូច្នេះការប្រមូលទិន្នន័យពីសហគ្រាសកសិកម្មខ្នាតធំបានត្រឹមចំនួន ៤៧០ កសិដ្ឋានប៉ុណ្ណោះ។

## រយៈពេល នៃការអង្កេត និងកាលបរិច្ឆេទយោង

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ត្រូវបានធ្វើឡើងជា២ដំណាក់កាល ៖ ដំណាក់កាលទី១ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ធ្វើការប្រមូលទិន្នន័យផ្តោតលើការកាន់កាប់ សហគ្រាសកសិកម្មខ្នាតធំតែប៉ុណ្ណោះ។ ដំណាក់កាលទី២ គិតចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ការចុះសម្ភាសប្រមូលទិន្នន័យលើការកាន់កាប់កសិកម្មលក្ខណៈគ្រួសារ។

រយៈពេល១២ខែកន្លងមក គិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ត្រូវបានកំណត់ជាកាលបរិច្ឆេទយោងសម្រាប់ការប្រមូលទិន្នន័យនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយសូចនាករមួយចំនួនបានបញ្ជាក់ពេលវេលាជាក់លាក់ដោយមិនបានប្រើកាលបរិច្ឆេទយោងទេ។ ដូច្នេះ

សម្រាប់ទិន្នន័យអំពីសូចនាករនោះប្រើប្រាស់ទៅតាមការចាំបាច់។ ឧទាហរណ៍៖ ចំនួនបសុសត្វ បសុបក្សីដែលមាននៅថ្ងៃសម្ភាសន៍ ដោយគិតយកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ ជាកាលបរិច្ឆេទយោង។

## តារាងបញ្ជីសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ត្រូវបានប្រើប្រាស់បញ្ជីមេជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដើម្បីធ្វើការជ្រើសរើសសំណាកគំរូ ។ ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ បានប្រើបញ្ជីឈ្មោះមណ្ឌលជំរឿននៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣។ បញ្ជីឈ្មោះមណ្ឌលជំរឿននេះមាន

ប្រមាណ ១៤.៥០០ ភូមិ និង ៣៨.០០០ មណ្ឌលជំរឿន។ សម្រាប់ភូមិនីមួយៗ មានការប្រមូលយកព័ត៌មានដូចតទៅ៖ រាជធានី/ខេត្ត ក្រុង/ខណ្ឌ/ស្រុក ឃុំ/សង្កាត់ (ជនបទ/ទីប្រជុំជន) ចំនួនមណ្ឌលជំរឿន និងចំនួនគ្រួសារសរុប។ ប្រជាជនជាគោលដៅ គឺគ្រួសារដែលប្រកបរបរកសិកម្ម វារីវប្បកម្ម និង/ឬនេសាទ។ មានភូមិមួយចំនួននៅទីជនបទដែលស្ថិតនៅក្នុងក្រុង/ស្រុកទីប្រជុំជនមិនត្រូវបានរាប់បញ្ចូលក្នុងការអង្កេតនេះ៖

- ខេត្តព្រះសីហនុ ក្រុងព្រះសីហនុ
- ខេត្តសៀមរាប ក្រុងសៀមរាប
- រាជធានីភ្នំពេញ ខណ្ឌចំការមន
- រាជធានីភ្នំពេញ ខណ្ឌដូនពេញ
- រាជធានីភ្នំពេញ ខណ្ឌ៧មករា
- រាជធានីភ្នំពេញ ខណ្ឌទួលគោក
- រាជធានីភ្នំពេញ ខណ្ឌឬស្សីកែវ
- រាជធានីភ្នំពេញ ខណ្ឌច្បារអំពៅ

ទោះជាមិនអាចដឹងមុននៃចំនួនគ្រួសារជនបទក្នុងមណ្ឌលជំរឿននីមួយៗក៏ដោយ ក៏យើងអាចគណនាបាននូវចំនួនគ្រួសារជនបទនៅតាមខេត្តនីមួយៗ ដោយបូកចំនួនគ្រួសារនៅក្នុងភូមិដែលត្រូវបានចាត់ថ្នាក់ជាគ្រួសារជនបទបានដែរ។ ការចុះស្រង់បញ្ជីគ្រួសារនៅក្នុងមណ្ឌលជំរឿននីមួយៗត្រូវបានធ្វើសម្រាប់ការអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ដើម្បីកំណត់អត្តសញ្ញាណប្រជាជនគោលដៅ ពោលគឺគ្រួសារដែលបានចូលរួមក្នុងសកម្មភាពកសិកម្ម។ សម្រាប់ការអង្កេតនេះ ពុំមានការកំណត់កម្រិត ចំនួន ទំហំផ្ទៃដី នៃសកម្មភាពកសិកម្ម ដើម្បីចាត់ចូលជាគ្រួសារកសិកម្មឡើយ។ ចំណុចនេះខុសគ្នាពីនីតិវិធីដែលបានប្រើក្នុងជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៣ និងជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០២៣ ដែលការសម្ភាសបានធ្វើចំពោះតែគ្រួសារដែលបានដាំដំណាំលើផ្ទៃដីយ៉ាងហោចណាស់ ០,០៣ ហិកតា និង/ឬមានបសុសត្វធំចំនួន ២ និង/ឬ បសុសត្វតូចចំនួន ៣ និង/ឬ បសុបក្សីចំនួន ២៥ ក្បាលយ៉ាងតិច។ សម្រាប់ដំណើរការអង្កេតកសិកម្មកម្ពុជាប្រចាំឆ្នាំ គឺមិនបានកំណត់លើទំហំផ្ទៃដីអតិបរិមាទេ ចំនួនបសុសត្វ បសុបក្សីដែលមានចិញ្ចឹម

មានចំនួនតិច ក៏ចាត់ជាគ្រួសារកសិកម្មផងដែរ ធ្វើដូចនេះដើម្បីផ្តល់ឱកាសដល់គ្រួសារកសិកម្មតូចៗត្រូវបានជ្រើសរើសជាសំណាកគំរូក្នុងអង្កេតនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយផ្អែកលើនីតិវិធី នៃការជ្រើសយកសំណាកត្រូវបានពន្យល់លម្អិតខាងក្រោម ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារដែលមានផ្ទៃដីធំ ឬចំនួនបសុសត្វ ឬបសុបក្សីច្រើនត្រូវបានកំណត់អត្តសញ្ញាណ និងបញ្ចូលក្នុងក្រុមសំណាកផ្សេងគ្នា ដើម្បីអាចជ្រើសយកបានគ្រួសារកសិកម្មទាំងនោះ។

## វិធីសាស្ត្រជ្រើសរើសសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកគំរូពីរ ដំណាក់កាលទី១ ជ្រើសរើសយកមណ្ឌលជំរឿន ដំណាក់កាលទី២ ជ្រើសរើសយកគ្រួសារកសិកម្ម។ មណ្ឌលជំរឿនចំនួន
១.៣៨១ ត្រូវបានជ្រើសរើសសម្រាប់អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ហើយមណ្ឌលជំរឿននីមួយៗត្រូវបានជ្រើសយកចំនួន១២ គ្រួសារកសិកម្ម សម្រាប់ធ្វើការសម្ភាសប្រមូលព័ត៌មានលម្អិត។ ដូច្នេះអង្កេតកសិកម្ម កម្ពុជា ឆ្នាំ២០២១ បានជ្រើសរើសទំហំគ្រួសារសំណាកគំរូសរុបចំនួន ១៦.៥៧២ គ្រួសារ នៅទូទាំងប្រទេស។ ភូមិ ឬមណ្ឌលជំរឿនចំនួន ១.៣៨១ ត្រូវបានជ្រើសរើសដោយវិធីសាស្ត្រចៃដន្យ គ្រប់រាជធានី ខេត្ត តាម សមាមាត្រនៃចំនួនគ្រួសារជនបទក្នុងខេត្តទាំងនោះ។ តារាងទី១ខាងក្រោមបង្ហាញបំណែងចែកស្តីពីការជ្រើសរើសសំណាកគំរូសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១។ ដើម្បីជ្រើសរើសមណ្ឌលជំរឿននៅក្នុងរាជធានី ខេត្ត ឈ្មោះភូមិទាំងអស់ត្រូវបានតម្រៀបតាមលំដាប់លេខកូដភូមិសាស្ត្រ ស្រុក ឃុំ និងដៅសម្គាល់ថា ភូមិស្ថិតនៅទីជនបទ-ទីប្រជុំជន។ បន្ទាប់មកធ្វើការជ្រើសរើសសំណាកជាលក្ខណៈប្រព័ន្ធចៃដន្យតាមទំហំគ្រួសារ ដោយ គិតសមាមាត្រប្រហាក់ប្រហែលគ្នា។ស

**តារាងទី១.៦ ការបែងចែកសំណាកគំរូ**

| រាជធានី/ខេត្ត | ចំនួនសរុបនៃគ្រួសារកសិកម្មពីជំរឿនកសិកម្មឆ្នាំ ២០១៣ | ចំនួន EA ដែលបានជ្រើសរើសសំណាកគំរូ CIAS ២០១៩ | ចំនួនគ្រួសារកសិកម្មដែលបានជ្រើសរើសសំណាកគំរូ CIAS ២០១៩ | ចំនួនគ្រួសារកសិកម្មដែលបានសម្ភាសន៍ CAS ២០២០ | ចំនួន EA ដែលបានជ្រើសរើសសំណាកគំរូ CIAS ២០២១ | ចំនួនគ្រួសារកសិកម្ម ដែលបានសម្ភាសន៍ CAS ២០២១ |
|---|---|---|---|---|---|---|
| **តំបន់វាលទំនាប** | 1,252,491 | 615 | 7,174 | 6,652 | 577 | 6,959 |
| ភ្នំពេញ | 60.000 | 50 | 394 | 342 | 23 | 312 |
| ព្រៃវែង | 268,473 | 127 | 1,524 | 1,406 | 127 | 1,524 |

| | | | | | | |
|---|---|---|---|---|---|---|
| ស្វាយរៀង | 124,656 | 59 | 708 | 673 | 59 | 708 |
| តាកែវ | 206,084 | 98 | 1,176 | 1,110 | 98 | 1,175 |
| ត្បូងឃ្មុំ | 167,628 | 79 | 948 | 863 | 79 | 948 |
| កណ្ដាល | 205,812 | 98 | 1,176 | 1,094 | 98 | 1,176 |
| កំពង់ចាម | 219,838 | 104 | 1,248 | 1,164 | 93 | 1,116 |
| **តំបន់បឹងទន្លេសាប** | 916,840 | 444 | 5,328 | 4,820 | 458 | 5,489 |

| | | | | | | |
|---|---|---|---|---|---|---|
| ប៉ៃលិន | 7,575 | 12 | 144 | 133 | 25 | 300 |
| បន្ទាយមានជ័យ | 122,230 | 58 | 696 | 607 | 58 | 696 |
| បាត់ដំបង | 209,719 | 99 | 1,188 | 1078 | 99 | 1185 |
| ឧត្ដរមានជ័យ | 43,614 | 21 | 252 | 212 | 21 | 252 |
| សៀមរាប | 163,620 | 78 | 936 | 871 | 78 | 936 |
| កំពង់ឆ្នាំង | 119,924 | 57 | 684 | 644 | 58 | 693 |
| កំពង់ធំ | 153,243 | 73 | 876 | 796 | 73 | 875 |
| ពោធិ៍សាត់ | 96,915 | 46 | 552 | 479 | 46 | 552 |
| **តំបន់ឆ្នេរសមុទ្រ** | 178,760 | 105 | 1,260 | 1,141 | 132 | 1,595 |
| កំពត | 135,273 | 64 | 768 | 702 | 78 | 948 |
| កែប | 4,316 | 10 | 120 | 111 | 13 | 156 |
| កោះកុង | 17,483 | 15 | 180 | 160 | 25 | 299 |
| ព្រះសីហនុ | 21,688 | 16 | 192 | 168 | 16 | 192 |
| **តំបន់ភ្នំ និងខ្ពង់រាប** | 372,578 | 186 | 2,232 | 2,109 | 209 | 2,520 |
| កំពង់ស្ពឺ | 164,840 | 78 | 936 | 897 | 77 | 936 |
| ក្រចេះ | 79,043 | 38 | 456 | 426 | 38 | 456 |
| មណ្ឌលគិរី | 16,413 | 14 | 168 | 154 | 17 | 204 |
| ព្រះវិហារ | 49,075 | 23 | 276 | 273 | 35 | 420 |

| | | | | | | |
|---|---|---|---|---|---|---|
| រតនគិរី | 36,904 | 17 | 204 | 182 | 25 | 300 |
| ស្ទឹងត្រែង | 26,303 | 16 | 192 | 177 | 17 | 204 |
| **សរុប** | 2,720,669 | 1,350 | 15,994 | 14,722 | 1,376 | 16,563 |

## នីតិវិធីគណនាមេគុណ និងការប៉ាន់ស្មាន

នីតិវិធីនៃការជ្រើសរើសសំណាកគំរូ និងការចាត់ថ្នាក់ ដូចដែលបានរៀបរាប់លម្អិតខាងលើ បានបង្ហាញថាមានប្រូបាប៊ីលីតេនៃការជ្រើសរើសគ្រួសារកសិកម្មមានក្នុងកម្រិតខុសៗគ្នា។ ដោយពិចារណាចំណុចនេះ ការគណនាមេគុណត្រូវបានធ្វើឡើង សម្រាប់គ្រួសារកសិកម្មនីមួយៗនៅក្នុងសំណាក និងបានអនុវត្តន៍ចំពោះទិន្នន័យដែលបានរាយការណ៍សម្រាប់កំណត់ត្រានោះ។ បន្ទាប់មកមេគុណសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ត្រូវបានកែតម្រូវសម្រាប់ករណីគ្មានចម្លើយ និងការខូចគុណភាព ហើយបានក្រិតតាមខ្នាត ដោយប្រើចំនួនគ្រួសារកសិកម្មតាមខេត្តដែលទទួលបានតាមរយៈជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩។ ជាចុងក្រោយ ទិន្នន័យដែលបានរាយការណ៍នេះ ត្រូវបានបូកសរុបនៅកម្រិតខេត្ត តំបន់ និងថ្នាក់ជាតិ។

## វិធីសាស្រ្តសម្រាប់ការសម្ភាសសហគ្រាសកសិកម្មខ្នាតធំ

បញ្ជីឈ្មោះមណ្ឌលជំរឿនសម្រាប់ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ត្រូវបានបង្កើតឡើងដោយផ្អែកតាមបញ្ជីដែលបានពីស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា រួមទាំងនាយកដ្ឋាននានានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ បញ្ជីឈ្មោះនេះបានរួមបញ្ចូលគ្នាផងដែរ នូវសហគ្រាសកសិកម្មខ្នាតធំដែលបានសម្ភាសន៍ក្នុងអំឡុងជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ និងអង្កេតកសិកម្មឆ្នាំ២០២០ផងដែរ។ បញ្ជីឈ្មោះសហគ្រាសកសិកម្មខ្នាតធំត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់ការអង្កេតកសិកម្ម ឆ្នាំ២០២១ គឺមានចំនួនរហូតដល់ ៤៧០ សហគ្រាសកសិកម្ម គឺមានចំនួនច្រើនជាងកាលពីការអង្កេតកសិកម្មឆ្នាំ២០២០ ដែលមានចំនួនតែ ២៨៥ ប៉ុណ្ណោះ។ ប្រតិបត្តិការសម្ភាសន៍សហគ្រាសកសិកម្មខ្នាតធំត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ បានសម្ភាសន៍ចំនួន ៤៧០ សហគ្រាសកសិកម្ម ។

## នីតិវិធី នៃការអង្កេត

ទិន្នន័យទាំងអស់នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ត្រូវបានប្រមូលទិន្នន័យតាមរយៈការបញ្ជូនមន្ត្រីសម្ភាសន៍ទៅសម្ភាសន៍ដោយផ្ទាល់ជាលក្ខណៈបុគ្គល ដោយប្រើកុំព្យូទ័រ (CAPI) ជាជំនួយដោយមានមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ និងមន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ជាអ្នកត្រួតពិនិត្យផ្ទាល់ ដោយទទួលបានការបណ្តុះបណ្តាលច្បាស់លាស់ ហើយអ្នកឆ្លើយតបសម្ភាសន៍ជាបុគ្គលពេញវ័យមានចំណេះដឹងគ្រប់គ្រាន់អំពីសកម្មភាពកសិកម្មក្នុងកសិដ្ឋាន អ្នកឆ្លើយតបសម្ភាសន៍ជាម្ចាស់កសិដ្ឋានត្រូវបានផ្តល់អាទិភាពឲ្យចូលរួម។ ក្នុងករណីម្ចាស់កសិដ្ឋានអវត្តមានអាចសម្ភាសន៍ ប្តី/ប្រពន្ធ ឬសមាជិកគ្រួសារ ដែលមានចំណេះដឹង អាចឆ្លើយតបសម្ភាសន៍បានផងដែរ។ មានការណែនាំថា ពុំត្រូវធ្វើសម្ភាសន៍ ឬសួរព័ត៌មានពីអ្នកជិតខាង ឬគ្រួសារផ្សេងទៀតឡើយ អំពីការកាន់កាប់កសិកម្មដែលកំពុងស្ថិតក្នុងការអង្កេតនេះ។

ទិន្នន័យក្នុងការអង្កេតនេះត្រូវបានសម្ភាសន៍ដោយប្រើប្រាស់កម្រងសំណួរគោល ដែលមានពន្យល់លម្អិតនៅក្នុងឯកសារសៀវភៅណែនាំមន្ត្រីសម្ភាសន៍នៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ដែលចែងពីទស្សនទាន និយមន័យ និងនីតិវិធីដែលត្រូវអនុវត្ត សម្រាប់ការប្រមូលទិន្នន័យ។ សេចក្តីព្រាងកម្រងសំណួរ និងឯកសារណែនាំ ត្រូវបានរៀបចំឡើងដោយផ្អែកលើអនុសាសន៍អំពីតម្រូវការទិន្នន័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគម្រោងគំនិតផ្តួចផ្តើម ៥០ x ២០៣០ ដើម្បីបំពេញកង្វះខាតទិន្នន័យកសិកម្ម។ កម្រងសំណួរ និងឯកសារណែនាំស្តីពីការប្រមូលទិន្នន័យនៃអង្កេតកសិកម្មកម្ពុជា ត្រូវបានកែសម្រួលដោយផ្អែកលើបទពិសោធន៍ និងលទ្ធផលដែលទទួលបានក្នុងអំឡុងពេលសម្ភាសន៍សាកល្បងចំនួនពីរដង។ឯកសារណែនាំអ្នកប្រមូលទិន្នន័យនៃអង្កេតកសិកម្មកម្ពុជា ត្រូវបានបំពេញបន្ថែមដោយការត្រួតពិនិត្យលើភាពស៊ីសង្វាក់គ្នានៃទិន្នន័យ ដែលធ្វើឡើងពីចម្ងាយដោយក្រុមអ្នកគ្រប់គ្រងទិន្នន័យ និងនៅក្នុងដំណើរការផ្ទៀងផ្ទាត់ទិន្នន័យជាបន្តបន្ទាប់នៅពេលក្រោយមក។

ទិន្នន័យដែលប្រមូលបានទាំងអស់ ត្រូវបានរក្សាទុកនៅលើម៉ាស៊ីនមេ (Cloud) របស់ Amazon ។ អ្នកគ្រប់គ្រងម៉ាស៊ីនមេ អាចទាញយកទិន្នន័យនេះក្នុងទម្រង់ផ្សេងៗ នៅពេលណាមួយក្នុងអំឡុងពេលប្រមូលទិន្នន័យ និងរហូតដល់ខែវិច្ឆិកា ឆ្នាំ២០២២ នៅពេលដែលម៉ាស៊ីនមេត្រូវបានបិទ។

## យន្តការជំនួយក្នុងការសម្ភាស

មុននឹងចាប់ផ្តើមចុះសម្ភាសន៍ប្រមូលទិន្នន័យតាមមូលដ្ឋាន គម្រោងអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ បានទទួលលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចែកជូនដល់មន្ត្រីនៅមូលដ្ឋាន និងអ្នកតបសម្ភាសន៍ទៅតាមការចាំបាច់ ដើម្បីទទួលកិច្ចសហការពីគ្រប់គ្រួសារសម្ភាសន៍ និងសហគ្រាសកសិកម្មនានាដែលធ្វើសកម្មភាពកសិកម្មនៅក្នុងប្រទេស។

## ប្រតិបត្តិការប្រមូលទិន្នន័យ

